Oregon Department of Human Services
OFFICE OF DEVELOPMENTAL DISABILITIES SERVICES

# សៀវភៅណែនាំអំពី ការតស៊ូមតិ ដោយខ្លួនឯង

## ចំពោះសេវាកម្មពិការភាពខាងបញ្ញា និងការលូតលាស់ (I/DD)

តើអ្នកមានសំណួរអំពីសេវាកម្ម I/DD របស់អ្នកដែរទេ?

យើងនៅទីនេះដើម្បីជួយអ្នកឱ្យក្លាយជាអ្នកទទួលខុសត្រូវ!



## សៀវភៅណែនាំនេះនឹងជួយអ្នកឱ្យយល់ថា៖

- តើសេវាកម្ម I/DD គឺជាអ្វី?
- តើសេវាកម្ម I/DD ដំណើរការយ៉ាងដូចម្ដេច?
- តើអ្នកអាចត្រៀមខ្លួនក្នុងការប្រើប្រាស់សេវាកម្ម I/DD យ៉ាងដូចម្ដេច?
- សំណួរដែលត្រូវសួរខ្លួនឯងនៅពេលរៀបចំផែនការរបស់អ្នក

> “វាជារឿងសំខាន់សម្រាប់អ្នកដែលត្រូវដឹងអំពីសេវាកម្មដែលមានសម្រាប់អ្នក ហើយមានអារម្មណ៍ជឿជាក់ក្នុងការប្រើប្រាស់សេវាទាំងនោះ។”
>
> - ភាពជាអ្នកដឹកនាំ ODDS

# តារាងមាតិកា

## តើអ្នកអាចរំពឹងអ្វីខ្លះ?


**01** **ការតស៊ូមតិដើម្បីជីវិតល្អរបស់អ្នក** **1-5**
តើការជាអ្នកតស៊ូមតិដោយខ្លួនឯងមានន័យដូចម្ដេច?

**02** **ការណែនាំអំពីសេវាកម្ម I/DD** **6-11**
តើសេវាកម្ម I/DD អាចធ្វើអ្វីសម្រាប់អ្នក?

**03** **ការវាយតម្លៃអំពីសេចក្ដីត្រូវការរបស់ Oregon (ONA)** **12-16**
តើអ្នកអាចត្រៀមខ្លួនសម្រាប់ ONA របស់អ្នកដោយរបៀបណា?

**04** **កិច្ចប្រជុំផែនការគាំទ្របុគ្គល (ISP)** **17-21**
តើអ្នកអាចសម្រេចបានជីវិតដែលអ្នកចង់បានដោយរបៀបណា?

**05** **ការតស៊ូមតិដោយខ្លួនឯងនៅក្នុងសេវាកម្ម I/DD** **22-26**
ចុះយ៉ាងណាបើការគាំទ្រដែលអ្នកទទួលបានមិនបំពេញតម្រូវការរបស់អ្នក?

# ការតស៊ូមតិដើម្បីជីវិតល្អរបស់អ្នក

01

## តើការតស៊ូមតិសម្រាប់ខ្លួនខ្ញុំមានន័យដូចម្តេច?

មនុស្សគ្រប់រូបសមនឹងទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរ។ អ្នកតស៊ូមតិដោយខ្លួនឯងល្អស្គាល់ខ្លួនឯង និងអាចប្រាស្រ័យទាក់ទងនូវអ្វីដែលពួកគេត្រូវការ។

ការតស៊ូមតិសម្រាប់តម្រូវការរបស់អ្នកអាចជួយឱ្យអ្នកមានអារម្មណ៍ជឿជាក់ជាងមុន និងផ្តល់ឱ្យអ្នកនូវឯករាជ្យភាពដែលអ្នកចង់បាន។





## តើខ្ញុំតស៊ូមតិដោយខ្លួនឯងដោយរបៀបណា?

មធ្យោបាយដ៏ល្អបំផុតដើម្បីស្វែងយល់អំពីរបៀបតស៊ូមតិសម្រាប់ខ្លួនអ្នកគឺ ត្រូវដឹងពីខ្លួនអ្នក និងតម្រូវការរបស់អ្នក។ កំណត់អត្តសញ្ញាណធនធាននៅក្នុងជីវិតរបស់អ្នកដែលជួយគាំទ្រដល់អ្នក។

## តើខ្ញុំមានធនធានអ្វីខ្លះក្នុងជីវិតរបស់ខ្ញុំ?



### ភាពខ្លាំង និងបទពិសោធន៍ផ្ទាល់ខ្លួន

ភាពខ្លាំងរបស់អ្នកអាចរួមមានដូចជា៖
ជំនាញ ចំណេះដឹង ឬបទពិសោធន៍ជីវិតរបស់អ្នក អ្វីដែលអ្នកពូកែ និងមានគុណសម្បត្តិដែលអ្នកដទៃកោតស្ញប់ស្ញែងចំពោះរូបអ្នក។

## ទំនាក់ទំនងគាំទ្រ



វាជាការសំខាន់ដែលត្រូវដឹងថា តើមានអ្នកណាខ្លះនៅក្នុងជីវិតរបស់អ្នកដែលជួយគាំទ្រអ្នក។
ពួកគេអាចជាមិត្តភក្តិរបស់អ្នក អ្នកតស៊ូមតិដោយខ្លួនឯងផ្សេងទៀត និងក្រុមគ្រួសារ។




## ការគាំទ្រដែលផ្អែកលើសិទ្ធិទទួលបាន

ទាំងនេះគឺជាសេវាកម្មដែលមានសម្រាប់អ្នក ដោយសារអាយុ ប្រាក់ចំណូល ឬពិការភាពរបស់អ្នកដូចជា៖

- ការប្រើប្រាស់ SNAP (កម្មវិធី ជំនួយអាហារូបត្ថម្ភបន្ថែម) ដើម្បីទិញគ្រឿងទេស
- សេវាកម្មពីការិយាល័យសេវាកម្មពិការភាពផ្នែកលូតលាស់ (ODDS)

## សហគមន៍ដែលអ្នកជាសមាជិក



សហគមន៍អាចជាកន្លែងដែលអ្នកទៅលេងញឹកញាប់ ដូចជា បរិវេណអាផាត់មិន សាលារៀន ឬកន្លែងគោរពបូជារបស់អ្នក។ វាក៏អាចជាក្រុមមួយផងដែរ ដូចជាសហគមន៍ LGBTQIA+ ក្លឹបហាត់ប្រាណរបស់អ្នក ឬថ្នាក់សិល្បៈរបស់អ្នក។



## បច្ចេកវិទ្យាមានប្រយោជន៍

មានបច្ចេកវិទ្យាជាច្រើនប្រភេទផ្សេងៗគ្នា។ អ្នកអាចមានស្មាតហ្វូន ឬថេប្លេតដែលមានកម្មវិធីដែលជួយអ្នកក្នុងការប្រាស្រ័យទាក់ទង ឬជួយដល់ពិការភាពរបស់អ្នក។
អ្នកក៏អាចមានឧបករណ៍សម្របខ្លួនដើម្បីជួយអ្នកផងដែរ ដូចជាឧបករណ៍សម្រាប់កាត់អាហារជាដើម។

# សន្លឹកកិច្ចការ៖

## តើមានធនធានអ្វីខ្លះដែលខ្ញុំអាចប្រើក្នុងជីវិត ដើម្បីតស៊ូមតិសម្រាប់ខ្លួនខ្ញុំ?

នៅពេលដែលអ្នកស្គាល់ខ្លួនឯង និងធនធានដែលអ្នកមានក្នុងជីវិតរបស់អ្នក អ្នកអាចតស៊ូមតិសម្រាប់សិទ្ធិ និងតម្រូវការរបស់អ្នកបាន។

### រៀបចំធនធានដែលអ្នកមានក្នុងជីវិតរបស់អ្នកខាងក្រោម!

**ភាពខ្លាំងផ្ទាល់ខ្លួន**

តើអ្នកពូកែអ្វីខ្លះ?

**ទំនាក់ទំនងគាំទ្រ**

តើមាននរណាខ្លះនៅក្នុងជីវិតរបស់អ្នកដែលជួយ និងលើកទឹកចិត្តអ្នក?



**ការគាំទ្រដែលផ្អែកលើសិទ្ធិទទួលបាន**

តើអ្នកមាន ឬចង់បានការគាំទ្រដោយផ្អែកលើសិទ្ធិទទួលបានអ្វីខ្លះ?

## បណ្ដាសហគមន៍ដែលអ្នកជាសមាជិក

តើអ្នកចង់ក្លាយជាផ្នែក ឬចូលរួមក្នុងសហគមន៍មួយណា?



## បច្ចេកវិទ្យាមានប្រយោជន៍

តើបច្ចេកវិទ្យាអ្វីខ្លះដែលជួយដល់អ្នក? តើអ្នកអាចសួរអំពី
បច្ចេកវិទ្យាផ្សេងៗពីនរណា?





# ធនធានបន្ថែម

យើងសង្ឃឹមថា ការតស៊ូមតិនេះសម្រាប់ផ្នែកជីវិតដ៏ល្អរបស់អ្នកជួយអ្នក នៅពេលអ្នកនិយាយជាមួយក្រុមរៀបចំផែនការរបស់អ្នក។ សូមចូលមើលធនធានខាងក្រោម ដើម្បីស្វែងយល់បន្ថែម។

### ធនធានចម្រុះទូទាំងរដ្ឋអំពីការតស៊ូមតិដោយខ្លួនឯងរបស់ Oregon

https://www.askosac.org/state-wide-resources/

### ក្រុមប្រឹក្សារដ្ឋ Oregon ផ្នែកពិការភាពខាងការលូតលាស់

https://www.ocdd.org/

### សិទ្ធិជនពិការ Oregon

https://www.droregon.org/

### តើធ្វើដូចម្ដេចដើម្បីក្លាយជាអ្នកតស៊ូមតិដោយខ្លួនឯង?

https://youtu.be/QWDR1etpYI-w?si=57h8xmlWF4G-GR-C

## ស្កែនកូដ QR ដើម្បីចូលទៅកាន់គេហទំព័ររបស់យើង និងមើលវីដេអូនៃផ្នែកនេះ។

https://www.oregon.gov/odhs/idd/Pages/self-advocates.aspx

## ចងចាំថា នេះគឺជាជីវិតរបស់អ្នក...

អ្នកត្រូវជ្រើសរើសផ្លូវផ្ទាល់ខ្លួនរបស់អ្នក





# ការណែនាំអំពីសេវាកម្ម I/DD

02

## តើសេវាពិការភាពខាងបញ្ញា និងការលូតលាស់ (I/DD) គឺជាអ្វី?

ការិយាល័យសេវាកម្មពិការភាពផ្នែកលូតលាស់ (ODDS) របស់រដ្ឋ Oregon ផ្តល់សេវាកម្មដើម្បីជួយគាំទ្រដល់អ្នកមានពិការភាពខាងបញ្ញា និងការលូតលាស់ (I/DD) និងក្រុមគ្រួសាររបស់ពួកគេឱ្យរស់នៅតាមរបៀបដែលពួកគេចង់បាននៅក្នុងសហគមន៍របស់ពួកគេ។

**អង្គភាពគ្រប់គ្រងករណីជួយមនុស្សឱ្យចូលប្រើសេវាកម្ម I/DD។**

អ្នកអាចជ្រើសរើសអ្នកដែលនឹងផ្តល់សេវាកម្មគ្រប់គ្រងករណីរបស់អ្នក រួមទាំង៖






អ្នកសម្របសម្រួលសេវាកម្មនៅកម្មវិធីពិការភាពខាងលូតលាស់ក្នុងសហគមន៍ (CDDP)




ភ្នាក់ងារផ្ទាល់ខ្លួននៅភ្នាក់ងារកណ្តាលសម្រាប់សេវាកម្មគាំទ្រ




សេវាតាមផ្ទះដែលថែទាំហ្មត់ចត់សម្រាប់កុមារ និងសេវាស្នាក់នៅសម្រាប់កុមារ

## តើសេវាកម្ម I/DD ដំណើរការយ៉ាងដូចម្ដេច?

អ្នកអាចធ្វើការសន្ទនាជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ឬភ្នាក់ងារផ្ទាល់ខ្លួន ដើម្បីពិភាក្សាអំពីសេវាកម្មដែលជួយគាំទ្រអ្នកក្នុងការរស់នៅក្នុងផ្ទះ និងចូលរួម និងប្រើធនធានក្នុងសហគមន៍របស់អ្នក។

ទាំងនេះគឺជាសេវាកម្មមួយចំនួនដែលអ្នកអាចមានសិទ្ធិទទួលបាន អាស្រ័យលើតម្រូវការគាំទ្ររបស់អ្នក៖

### ការថែទាំសម្រាប់សកម្មភាពប្រចាំថ្ងៃ

អ្នកគាំទ្រជំនាញដែលមានការបណ្ដុះបណ្ដាល ដែលជួយមនុស្សក្នុងការធ្វើ អ្វីៗដែលពួកគេធ្វើជារៀងរាល់ថ្ងៃ ដូចជា៖

- ការងូតទឹក
- ការស្លៀកពាក់
- ការចម្អិនម្ហូប
- ការគ្រប់គ្រងប្រាក់កាស
- ការប្រាស្រ័យទាក់ទង





### សេវាកម្មការងារ

ជួយគាំទ្រមនុស្សក្នុងការ៖

- រុករកការងារ
- ស្វែងរកការងារ
- និងរក្សាការងារ

## ការកែប្រែផ្ទះ និងឧបករណ៍ជំនួយ

**ឧបករណ៍ជំនួយ បច្ចេកវិទ្យា និងការកែប្រែផ្ទះ ជួយមនុស្សឱ្យមានឯករាជ្យ មានសុខភាពល្អ និងសុវត្ថិភាព ដូចជា៖**



- ប្រាប់ដំណឹង និងការក្រើនរំលឹក
- ឧបករណ៍ផ្ទះបាយដែលអាចបត់បែនបាន
- ជម្រាលសម្រាប់រទេះរុញ
- របារចាប់កាន់នៅក្នុងបន្ទប់ទឹក



## មធ្យោបាយធ្វើដំណើរ

**ជួយគាំទ្រមនុស្សជុំវិញសហគមន៍របស់ពួកគេ** ដូចជាទទួលបានសំបុត្រឡានក្រុងដើម្បីធ្វើដំណើរជុំវិញទីក្រុង។





## សេវាកម្មផ្សេងទៀត

**ទាំងនេះអាចរួមមានដូចជា៖**

- សេវាថែទាំសម្រាប់អ្នកដែលមានស្ថានភាពវេជ្ជសាស្ត្រមួយចំនួន
- ការគាំទ្រខាងអាកប្បកិរិយា
- ការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រ

## តើអ្នកអាចត្រៀមខ្លួនដើម្បីប្រើប្រាស់សេវាកម្ម I/DD យ៉ាងដូចម្ដេច?

ការមានចក្ខុវិស័យសម្រាប់អនាគតរបស់អ្នក អាចជួយឱ្យអ្នករក្សាការផ្ដោតអារម្មណ៍ និងសម្រេចបាននូវគោលដៅរបស់អ្នក។

### ចក្ខុវិស័យរបស់ខ្ញុំ

ផ្លូវទៅកាន់ចក្ខុវិស័យ

តើអ្នកចង់បានអ្វី?

តើអ្វីដែលអ្នកមិនចង់បាន?



### ចងចាំថា នេះគឺជាផែនការរបស់អ្នក...

គ្មានអ្វីដែលសំខាន់អំពីខ្ញុំត្រូវបានសម្រេចដោយគ្មានការចូលរួមពីខ្ញុំទេ

## សន្លឹកកិច្ចការ៖ ការបង្កើតផែនការរបស់អ្នកអំពីអ្នក

សំណួរដែលត្រូវគិតនៅពេលរៀបចំផែនការជីវិតដែលអ្នកចង់បាន៖

តើអ្នកចង់បានអ្វីក្នុងជីវិតរបស់អ្នក?

______________________

______________________

______________________

______________________

តើអ្នកមិនចង់បានអ្វីក្នុងជីវិតរបស់អ្នក?

______________________

______________________

______________________

______________________

តើមនុស្សចូលចិត្តអ្វីខ្លះពីអ្នក និងគោរពអ្នកបែបណា?



តើអ្វីដែលសំខាន់បំផុតសម្រាប់អ្នក?

តើអ្នកឯទៀតអាចជួយ និងលើកទឹកចិត្តអ្នកបានល្អបំផុតដោយរបៀបណា?



# ធនធានបន្ថែម

យើងសង្ឃឹមថា ផ្នែកណែនាំនេះអាចជួយអ្នកនៅពេលអ្នកនិយាយជាមួយក្រុមការងាររៀបចំផែនការរបស់អ្នក។ សូមចូលទៅកាន់ធនធានខាងក្រោម ដើម្បីស្វែងយល់បន្ថែមអំពីសេវាកម្ម I/DD។

### ការងារជាអាទិភាព

https://www.oregon.gov/odhs/employment-first/Pages/individuals.aspx

### ការសម្រេចចិត្តដែលមានជំនួយគាំទ្រសម្រាប់បុគ្គលម្នាក់ៗ

https://thearcoregon.org/wp-content/uploads/2019/10/Its-Your-Decision-v5.pdf

### បញ្ជីនៃ CDDPs និងភ្នាក់ងារកណ្ដាល

https://www.oregon.gov/odhs/idd/Pages/cddp.aspx

https://www.oregon.gov/odhs/idd/Pages/brokerage.aspx

## ស្កេនកូដ QR ដើម្បីចូលទៅកាន់គេហទំព័ររបស់យើង និងមើលវីដេអូនៃផ្នែកនេះ។

https://www.oregon.gov/odhs/idd/Pages/self-advocates.aspx

## ចងចាំថា នេះគឺជាជីវិតរបស់អ្នក...

អ្នកគួរតែបំពេញតម្រូវការរបស់អ្នក



# ការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon (ONA) 03

## តើការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon (ONA) គឺជាអ្វី?

ODDS ប្រើការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon (ONA) ដើម្បីស្វែងរកជំនួយដែលអ្នកត្រូវការពាក់ព័ន្ធនឹងកិច្ចការដែលអ្នកធ្វើជារៀងរាល់ថ្ងៃ។




## តើខ្ញុំធ្វើ ONA នៅពេលណា?

- ជាធម្មតាម្តងក្នុងមួយឆ្នាំ
- អ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ឬភ្នាក់ងារផ្ទាល់ខ្លួននឹងប្រាប់អ្នក ប្រសិនបើអ្នកត្រូវការធ្វើ ONA ច្រើនជាងម្តងក្នុងមួយឆ្នាំ

## តើនរណាធ្វើ ONA របស់ខ្ញុំ?

- អ្នកវាយតម្លៃ ONA
- អ្នកសម្របសម្រួលសេវាកម្ម ឬភ្នាក់ងារផ្ទាល់ខ្លួនរបស់អ្នក

## តើមានសំណួរអ្វីខ្លះនៅលើ ONA?

ONA សួរអ្នកអំពីផ្នែកផ្សេងៗនៃជីវិតរបស់អ្នក៖

- របៀបដែលអ្នកចូលចិត្តដើម្បីធ្វើការប្រាស្រ័យទាក់ទង
- កិច្ចការដែលអ្នកធ្វើជារៀងរាល់ថ្ងៃ
- កិច្ចការដែលអ្នកធ្វើដើម្បីថែទាំផ្ទះ និងទុកដាក់ប្រាក់កាសរបស់អ្នក
- ការគាំទ្រខាងអាកប្បកិរិយារបស់អ្នក
- សុវត្ថិភាព និងតម្រូវការផ្នែកវេជ្ជសាស្ត្ររបស់អ្នក



# តើដំណើរការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon (ONA) មានដំណើរការយ៉ាងដូចម្តេច?



## មុនពេល ONA របស់អ្នក

អ្នកវាយតម្លៃ ONA នឹងស្វែងយល់បន្ថែមអំពីអ្នកដើម្បីត្រៀមខ្លួនឱ្យបានរួចរាល់ក្នុងការសួរអ្នកនូវសំណួរនានានៅលើ ONA។



## អំឡុងពេល ONA របស់អ្នក

- អ្នកវាយតម្លៃ ONA នឹងសួរអ្នកនូវសំណួរនានា និងធ្វើការកត់ត្រា
- អ្នកអាចអញ្ជើញអ្នកដែលស្គាល់អ្នក ច្បាស់ជាងគេ ឱ្យមកគាំទ្រអ្នក
- អ្នកអាចសុំសម្រាកបាន

## បន្ទាប់ពី ONA របស់អ្នក

- លទ្ធផលនៃ ONA របស់អ្នកនឹងដាក់អ្នកនៅក្នុងក្រុមសេវាកម្ម
- ក្រុមសេវាកម្មប្រាប់អ្នកពីចំនួនម៉ោងនៃការថែទាំ ដែលអ្នកប្រហែលជាត្រូវការជារៀងរាល់ខែ ហើយថាតើនរណាម្នាក់នឹងទទួលបានប្រាក់ប៉ុន្មានដើម្បីគាំទ្រអ្នកសម្រាប់សេវាកម្មខុសៗគ្នា




*ប្រសិនបើអ្នកមានសំណួរអំពី ONA របស់អ្នក អ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ឬភ្នាក់ងារផ្ទាល់ខ្លួនអាចឆ្លើយសំណួរទាំងនោះបាន!*

## តើអ្នកអាចត្រៀមខ្លួនសម្រាប់ ONA របស់អ្នកដោយរបៀបណា?

ការនិយាយអំពីតម្រូវការគាំទ្ររបស់អ្នកអាចនឹងពិបាក។ អ្នកប្រហែលជាមិនស្គាល់អ្នកវាយតម្លៃច្បាស់ទេ។

*តើមានអ្វី ឬនរណាម្នាក់ដែលធ្វើឱ្យការសន្ទនាទាំងនេះកាន់តែងាយស្រួលសម្រាប់អ្នកដែរទេ?*

### ចក្ខុវិស័យរបស់ខ្ញុំ

តើអ្នកចង់បាន និងត្រូវការជំនួយគាំទ្រអ្វីខ្លះ?

ផ្លូវទៅកាន់ចក្ខុវិស័យ

តើអ្វីដែលអ្នកមិនចង់បាន?



### ចងចាំថា នេះគឺអំពីអ្នក...

**ចំណូលចិត្តរបស់អ្នកគួរតែទទួលបានការគោរព**

## សន្លឹកកិច្ចការ៖ ការបង្កើតផែនការរបស់អ្នកអំពីអ្នក

តើការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon បន្ទាប់របស់អ្នកនឹងធ្វើនៅពេលណា?

____________________

តើកន្លែងណាដែលនឹងសុខស្រួលបំផុតសម្រាប់អ្នកដើម្បីធ្វើ ONA របស់អ្នក?

____________________

____________________

តើអ្នកចង់ជួបជាមួយអ្នកវាយតម្លៃ ONA តែម្នាក់ឯង ឬក៏ជាមួយអ្នកផ្សេងទៀត? តើអ្នកចង់ឱ្យនរណាអញ្ជើញចូលរួមនៅទីនោះ?

____________________

____________________

____________________

# សន្លឹកកិច្ចការ៖ ការបង្កើតផែនការរបស់អ្នកអំពីអ្នក

តើអ្នកចង់ឆ្លើយសំណួរនៅលើ ONA ដោយខ្លួនឯងដែរទេ? ឬអ្នកចង់ឱ្យអ្នកដែលអ្នកទុកចិត្តឆ្លើយជំនួសអ្នក?

តើមានប្រធានបទដែលអ្នកមិនចង់ពិភាក្សាដែរទេ? បើដូច្នេះ តើអ្នកចង់ឱ្យអ្នកណាតស៊ូមតិឱ្យអ្នក?



តើមានអ្វីដែលអ្នកចង់ឱ្យអ្នកវាយតម្លៃ ONA ដឹងអំពីអ្នកទេ?

**ការគិតអំពីតម្រូវការគាំទ្ររបស់អ្នក៖**

តើអ្នកត្រូវការមនុស្សច្រើនជាងម្នាក់ដើម្បីជួយគាំទ្រអ្នកទេ?

តើអ្នកត្រូវការជំនួយគាំទ្រពេញមួយយប់ដែរទេ?



# ធនធានបន្ថែម

យើងសង្ឃឹមថា ផ្នែក ONA នេះអាចជួយអ្នកនៅពេលអ្នកនិយាយជាមួយក្រុមការងាររៀបចំផែនការរបស់អ្នក។ សូមចូលទៅកាន់ធនធានខាងក្រោម ដើម្បីស្វែងយល់បន្ថែមអំពីការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon។

### គំនូសតាងចំនួនម៉ោងរបស់ក្រុមសេវាកម្ម

https://www.oregon.gov/odhs/compass/Documents/service-group-hours-table-color-en.pdf

### ការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon (គេហទំព័រ ODDS)

https://www.oregon.gov/odhs/compass/Pages/ona.aspx

### ស្កេនកូដ QR ដើម្បីចូលទៅកាន់គេហទំព័ររបស់យើង និងមើលវីដេអូនៃផ្នែកនេះ។

https://www.oregon.gov/odhs/idd/Pages/self-advocates.aspx

### ចងចាំថា នេះគឺជាផែនការរបស់អ្នក...

អ្នកត្រូវជ្រើសរើសផ្លូវផ្ទាល់ខ្លួនរបស់អ្នក





### ដឹងពីបញ្ជីត្រួតពិនិត្យសិទ្ធិរបស់អ្នក

☑អ្នកអាចសម្រេចចិត្តថា តើអ្នកចង់ឱ្យនរណាមក ឬមិនចង់ឱ្យនរណាមកនៅក្នុងការវាយតម្លៃ ONA របស់អ្នក។

☑អ្នកអាចសុំសម្រាកកំឡុងពេលប្រជុំរបស់អ្នក ឬសុំឱ្យបញ្ចប់ ONA នៅកិច្ចប្រជុំនៅពេលក្រោយ។

☑ប្រសិនបើអ្នកមិនយល់ស្របនឹងលទ្ធផល ONA របស់អ្នកទេ អ្នកអាចនិយាយជាមួយអ្នកសម្របសម្រួលសេវាកម្ម ឬភ្នាក់ងារផ្ទាល់ខ្លួនរបស់អ្នកបាន។

☑អ្នកអាចស្នើសុំអានច្បាប់ចម្លងនៃ ONA របស់អ្នកបាន។

☑ ប្រសិនបើតម្រូវការរបស់អ្នកនៅតែមិនត្រូវបានបំពេញ អ្នកអាចស្នើសុំការលើកលែង។

# ផែនការគាំទ្របុគ្គល (ISP)

04

## តើផែនការគាំទ្របុគ្គលជាអ្វី?

ផែនការគាំទ្របុគ្គល គឺត្រូវបានហៅថា “ISP" ឬ “ផែនការ"។ ISP គឺជាផ្នែកមួយដ៏សំខាន់ក្នុងការតស៊ូមតិសម្រាប់សេវាកម្ម និងជំនួយគាំទ្រដែលអ្នកចង់បាន។

ISP ជួយបុគ្គលម្នាក់ៗរៀបចំផែនការពីរបៀបដែលពួកគេចង់រស់នៅក្នុងជីវិតដ៏ល្អមួយ។ ISP របស់បុគ្គលម្នាក់ៗគឺខុសគ្នា ដោយសារតែបុគ្គលម្នាក់ៗមានលក្ខណៈខុសប្លែកពីគ្នា។



**ISP របស់អ្នកគួរតែជាអ្វីទាំងអស់អំពីអ្នក!**

វាមានព័ត៌មានអំពីគំនិតនៃជីវិតដ៏ល្អរបស់អ្នក ដូចជា៖



តើនរណា និងអ្វីសំខាន់បំផុតចំពោះអ្នក



សកម្មភាព និងសហគមន៍របស់អ្នក



វប្បធម៌ ឬសាសនារបស់អ្នក



ការប្រាស្រ័យទាក់ទង និងតម្រូវការផ្នែកភាសារបស់អ្នក



គោលដៅរបស់អ្នកដែលអ្នកចង់សម្រេចបាន



តើជំនួយគាំទ្រអ្វីខ្លះដែលអ្នកចង់បាន និងត្រូវការដើម្បីសម្រេចនូវគោលដៅរបស់អ្នក

## តើដំណើរការ ISP ដំណើរការដោយរបៀបណា?



- ក្នុងអំឡុងពេលកិច្ចប្រជុំ ISP របស់អ្នក អ្នកនឹងជួបជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ឬភ្នាក់ងារផ្ទាល់ខ្លួន និងអ្នកដែលស្គាល់អ្នកច្បាស់បំផុត ដើម្បីពិភាក្សាអំពីគោលដៅរបស់អ្នក
- អ្នកក៏នឹងសម្រេចចិត្តថា តើសេវាកម្មអ្វីខ្លះដែលអ្នកចង់បាន និងត្រូវការដើម្បីសម្រេចគោលដៅទាំងនោះ។

## ជារៀងរាល់ឆ្នាំ អ្នកនឹងបង្កើត ISP ថ្មីដែលគួរតែ៖

បន្តនូវអ្វីដែលកំពុងដំណើរការបានល្អ

ផ្លាស់ប្តូរអ្វីដែលមិនដំណើរការ

ជួយគាំទ្រអ្នកឱ្យសាកល្បងកិច្ចការថ្មីៗ

- អ្នកអាចមានតម្រូវការរយៈពេលខ្លី ឬសុបិនធំៗសម្រាប់អនាគតរបស់អ្នក
- ISP គឺជាផែនការរបស់អ្នក! ISP អាចជួយអ្នករៀបចំផែនការសម្រាប់គោលដៅរយៈពេលខ្លី ឬរយៈពេលវែងរបស់អ្នក។



## តើអ្នកអាចត្រៀមខ្លួនសម្រាប់កិច្ចប្រជុំ ISP របស់អ្នកដោយរបៀបណា?

- គិតអំពីគោលដៅរបស់អ្នក និងប្រភេទនៃជំនួយដែលអ្នកត្រូវការដើម្បីសម្រេចបានវា
- អញ្ជើញមិត្តភក្តិ ក្រុមគ្រួសារ និងអ្នកគាំទ្រមក ISP របស់អ្នក

### ចក្ខុវិស័យរបស់ខ្ញុំ




តើអ្នកចង់បានអ្វី?

តើអ្វីដែលអ្នកមិនចង់បាន?



### ចងចាំថា នេះគឺជាផែនការរបស់អ្នក...

អ្នកអាចសម្រេចចិត្តបានថា តើនរណាដែលអាចចូលរួមបាន

### សន្លឹកកិច្ចការ៖
### ការបង្កើតផែនការរបស់អ្នកអំពីអ្នក

តើអ្នកចង់ឱ្យកិច្ចប្រជុំ ISP របស់អ្នកកើតឡើងនៅពេលណា និងកន្លែងណា?

______________________________

______________________________

តើអ្នកចង់ក្លាយជានរណានៅក្នុងកិច្ចប្រជុំ ISP របស់អ្នក?

______________________________

______________________________

តើសេវាកម្មអ្វីខ្លះដែលអ្នកត្រូវការដើម្បីជួយអ្នកឱ្យសម្រេចបាននូវជីវិតដ៏ល្អរបស់អ្នក?

______________________________

## សន្លឹកកិច្ចការ៖ ការបង្កើតផែនការរបស់អ្នកអំពីអ្នក

តើមានអ្វីដែលធ្វើឱ្យការសន្ទនាទាំងនេះ កាន់តែងាយស្រួលសម្រាប់អ្នកទេ?

______________________________

______________________________

______________________________

តើក្រុមរបស់អ្នកអាចជួយគាំទ្រអ្នកក្នុងការសម្រេចចិត្តដោយរបៀបណា?

______________________________

______________________________

______________________________

______________________________



តើអ្នកមានគោលដៅអ្វីខ្លះសម្រាប់ឆ្នាំនេះ?

______________________________

______________________________

______________________________

______________________________

តើមានរឿងដែលអ្នកមិនចង់និយាយដែរទេ?

______________________________

______________________________

បើដូច្នេះ តើអ្នកនឹងចង់ឱ្យអ្នកណាតស៊ូមតិឱ្យអ្នក?

______________________________



# ធនធានបន្ថែម

យើងសង្ឃឹមថា ផ្នែក ISP នេះអាចជួយអ្នកនៅពេលអ្នកនិយាយជាមួយក្រុមការងាររៀបចំផែនការរបស់អ្នក។ សូមចូលមើលធនធានខាងក្រោម ដើម្បីស្វែងយល់បន្ថែមអំពី ISP។

### ទំព័រវិប ODDS ដែលមានព័ត៌មានបន្ថែមអំពី ISP

https://www.oregon.gov/odhs/compass/Pages/isp.aspx

### ការស្ទង់មតិអំពី ISP ដើម្បីចែករំលែកគំនិតរបស់អ្នកលើការកែលម្អ ISPs

https://www.surveymonkey.com/r/HLFXHLH

### គម្រោងរចនា ISP ឡើងវិញរបស់ Oregon

https://www.oregon.gov/odhs/compass/Documents/isp-redesign-infographic-en.pdf

### តើមានអ្វីនៅក្នុងផែនការរបស់អ្នក?

https://oregonisp.org/module/mod1/

### ស្កែនកូដ QR ដើម្បីចូលទៅកាន់គេហទំព័ររបស់យើង និងមើលវីដេអូនៃផ្នែកនេះ។

https://www.oregon.gov/odhs/idd/Pages/self-advocates.aspx

## ដឹងពីបញ្ជីត្រួតពិនិត្យសិទ្ធិរបស់អ្នក

☑ សំឡេង និងជម្រើសរបស់អ្នកគួរតែទទួលការគោរពជានិច្ច

☑ អ្នកអាចតស៊ូមតិសម្រាប់សិទ្ធិរបស់អ្នកដើម្បីចូលរួមក្នុងការធ្វើផែនការសេវាកម្មដែលបំពេញតម្រូវការរបស់អ្នក

☑ អ្នកអាចជ្រើសរើសពេលវេលា និងទីកន្លែងដើម្បីធ្វើការសន្ទនាអំពី ISP របស់អ្នក

☑ អ្នកអាចជ្រេសរើសរបៀបដែលការសម្រេចចិត្តនឹងត្រូវបានធ្វើឡើង

## ចងចាំថា នេះគឺជាផែនការរបស់អ្នក...

**អ្នកត្រូវជ្រើសរើសផ្លូវផ្ទាល់ខ្លួនរបស់អ្នក**



# សិទ្ធិ និងការមិនយល់ស្របរបស់អ្នកលើសេវាកម្ម I/DD

05

## តើខ្ញុំអាចធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំមិនយល់ស្របតាមអ្វីដែលមាននៅក្នុងផែនការ ឬ ONA របស់ខ្ញុំ?

មនុស្សគ្រប់រូបសមនឹងទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរ។ ការដឹងពីសិទ្ធិរបស់អ្នក និងការហ៊ាននិយាយចេញមក គឺជាវិធីមួយដើម្បីតស៊ូមតិសម្រាប់ខ្លួនអ្នក។

## តើខ្ញុំអាចរំពឹងអ្វីខ្លះពីសេវាកម្ម I/DD របស់ខ្ញុំ?

សេវាកម្ម I/DD របស់អ្នកគួរតែបំពេញតម្រូវការរបស់អ្នក និងជួយអ្នកឱ្យសម្រេចបាននូវគោលដៅរបស់អ្នក។ អ្នកគួរតែទទួលបានជំនួយគាំទ្រជានិច្ចដើម្បី៖



**ជ្រើសរើសថា នរណាដែល៖**

- **ស្ថិតក្នុងជីវិតរបស់អ្នក**
- **ផ្តល់ការថែទាំដល់អ្នក**
- **ជួយគាំទ្រក្នុងការសម្រេចចិត្តរបស់អ្នក**

**ឱ្យសំឡេង និងជម្រើសរបស់អ្នកទទួលបានការគោរព**



**បង្កើតផែនការគាំទ្របុគ្គល (ISP) ដែលផ្តោតលើគំនិតរបស់អ្នកអំពីជីវិតដ៏ល្អ។**

## តើអ្នកមានសិទ្ធិអ្វីខ្លះ ប្រសិនបើអ្នកមិនយល់ព្រមនឹងសេវាកម្ម I/DD របស់អ្នក?



និយាយជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ឬ ភ្នាក់ងារផ្ទាល់ខ្លួន ប្រសិនបើអ្នកមិនយល់ស្របនឹងលទ្ធផល ONA របស់អ្នក ជម្រើសសេវាកម្ម ឬមានកង្វល់ផ្សេងទៀត។

**អ្នកមានសិទ្ធិ៖**

- ផ្លាស់ប្តូរផែនការគាំទ្របុគ្គល (ISP) របស់អ្នក




- ស្នើសុំសេវាកម្មបន្ថែមតាមរយៈ ការលើកលែងមួយ




- ស្នើសុំការវាយតម្លៃអំពីសេចក្តីត្រូវការរបស់ Oregon (ONA) ថ្មី




- ទទួលបានការជូនដំណឹងជាមុន ប្រសិនបើសេវាកម្មរបស់អ្នកនឹងត្រូវបានកាត់បន្ថយ ផ្អាក ឬបញ្ចប់




- ដាក់ពាក្យបណ្តឹង និងទទួលបានជំនួយដើម្បីដោះស្រាយវា




- ស្នើសុំសវនាការជាមួយនឹងចៅក្រម

## តើអ្នកអាចត្រៀមខ្លួនដើម្បីតស៊ូមតិដោយខ្លួនឯងនៅក្នុងសេវាកម្ម I/DD យ៉ាងដូចម្តេច?

និយាយជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក និងភ្នាក់ងារផ្ទាល់ខ្លួន។ ពួកគេនៅទីនេះដើម្បីជួយអ្នកតស៊ូមតិសម្រាប់តម្រូវការរបស់អ្នក។

អ្នកក៏អាចសុំឱ្យអ្នកផ្សេងទៀតដែលអ្នកទុកចិត្ត ជួយអ្នក នៅពេលអ្នកតស៊ូមតិសម្រាប់ខ្លួនអ្នកផងដែរ



## ចក្ខុវិស័យរបស់ខ្ញុំ




តើអ្នកចង់បាន និងត្រូវការជំនួយគាំទ្រអ្វីខ្លះ?

តើអ្វីដែលអ្នកមិនចង់បាន?

**ចងចាំថា អ្នកមានសិទ្ធិ!**

អ្នកអាចតស៊ូមតិសម្រាប់ខ្លួនអ្នក

## សន្លឹកកិច្ចការ៖ ការបង្កើតផែនការរបស់អ្នកអំពីអ្នក

តើតម្រូវការរបស់អ្នកមានអ្វីខ្លះ?
តើតម្រូវការរបស់អ្នកកំពុងត្រូវបានបំពេញដែរទេ?

តើអ្នកចង់ធ្វើអ្វី ប្រសិនបើតម្រូវការរបស់អ្នកមិនត្រូវបានបំពេញ?

## សន្លឹកកិច្ចការ៖ ការបង្កើតផែនការរបស់អ្នកអំពីអ្នក

តើសេវាកម្ម និងជំនួយគាំទ្រអ្វីខ្លះ ដែលអាចជួយអ្នកបំពេញតម្រូវការ របស់អ្នក?

តើអ្នកមានអារម្មណ៍ថាស្រួល និយាយអំពីតម្រូវការរបស់អ្នកជា មួយអ្នកណា?



តើអ្នកត្រូវការការលើកលែងដែរទេ? តើមានតម្រូវការអ្វីខ្លះដែលមិនត្រូវបានបំពេញ?

តើអ្នកទុកចិត្តអ្នកណាដើម្បីជួយគាំទ្រអ្នកតាមរយៈ ការលើកលែង ឬដំណើរការបណ្ដឹង?



## ធនធានបន្ថែម

យើងសង្ឃឹមថា ផ្នែកនេះជួយអ្នកតស៊ូមតិដើម្បីបំពេញតម្រូវការរបស់អ្នក។
សូមចូលមើលធនធានខាងក្រោម ដើម្បីស្វែងយល់បន្ថែម។

### ទំព័រវិប ODDS ដែលមានព័ត៌មានបន្ថែមអំពីការលើកលែង

https://www.oregon.gov/odhs/idd/Pages/exceptions.aspx

### បណ្ដឹងអំពីសេវាកម្ម I/DD

https://www.oregon.gov/odhs/idd/Pages/complaints.aspx

### ដឹងពីបញ្ជីត្រួតពិនិត្យសិទ្ធិរបស់អ្នក

https://sharedsystems.dhsoha.state.or.us/DHSForms/Served/de-642931.pdf

### សវនាការរដ្ឋបាលសម្រាប់សេវាកម្ម I/DD

https://www.oregon.gov/odhs/idd/Pages/hearings.aspx

### ស្កែនកូដ QR ដើម្បីចូលទៅកាន់គេហទំព័ររបស់យើង និងមើលវីដេអូនៃផ្នែកនេះ។

https://www.oregon.gov/odhs/idd/Pages/self-advocates.aspx

### ដឹងពីបញ្ជីត្រួតពិនិត្យសិទ្ធិរបស់អ្នក

☑ សំឡេង និងជម្រើសរបស់អ្នកគួរតែទទួលការគោរពជានិច្ច។

☑ អ្នកអាចតស៊ូមតិសម្រាប់សិទ្ធិរបស់អ្នកដើម្បីចូលរួមក្នុងការធ្វើផែនការសេវាកម្មដែលបំពេញតម្រូវការរបស់អ្នក។

### ចងចាំថា នេះគឺជាផែនការរបស់អ្នក...

អ្នកត្រូវជ្រើសរើសផ្លូវផ្ទាល់ខ្លួនរបស់អ្នក





# តើមានវិធីណាដែលអាចមានប្រយោជន៍ជាងនេះទេ?

ODDS ផ្តល់ជំនួយដោយឥតគិតថ្លៃ ដើម្បីឱ្យអ្នកគ្រប់គ្នាអាចប្រើប្រាស់សេវាកម្មរបស់យើងបាន។

ឧទាហរណ៍មួយចំនួននៃជំនួយឥតគិតថ្លៃនេះរួមមាន៖

- អ្នកបកប្រែភាសាសញ្ញា និងអ្នកបកប្រែភាសានិយាយ
- ឯកសារជាលាយលក្ខណ៍អក្សរជាភាសាផ្សេងទៀត
- អក្សរស្ទាប ឬអក្សរធំ
- អូឌីយ៉ូ និងទម្រង់ផ្សេងទៀត

**ទាក់ទងមកយើងតាម៖**

ODDS.Questions@odhsoha.oregon.gov

ឬហៅទូរសព្ទទៅលេខ 503-945-5811។ យើងក៏ទទួលការហៅបញ្ជូនបន្តទាំងអស់។

## សំណួរនានាអំពីសេវាកម្មរបស់អ្នក?

និយាយជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ឬភ្នាក់ងារផ្ទាល់ខ្លួន។ ពួកគេនៅទីនេះដើម្បីជួយគាំទ្រអ្នក។

Oregon Department of Human Services
OFFICE OF DEVELOPMENTAL DISABILITIES SERVICES



ការិយាល័យសេវាកម្មពិការភាពផ្នែកលូតលាស់

www.oregon.gov/odhs/idd/

503-945-5811